នាយកដ្ឋាន នីតិវិធី
ទទួល
លេខ: ២៤
ថ្ងៃទី ០៣/០៨ ១១ ម៉ោង ៥:០០
ហត្ថលេខា:.....................

# ព្រះរាជក្រម

នស/រកម/០៧១១/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ៣ ធ្វើ
# វិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព
# និងសហប្រតិបត្តិការនៅ
# អាស៊ីអាគ្នេយ៍

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ដែលបានចុះហត្ថលេខានៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៤០ ខែ កក្កដា ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.១១០៧.៦៩៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ហត្ថលេខា

ហោ ណាំហុង

លេខៈ ៧៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

2/2W

## ពិធីសារទី៣

## ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍

ប្រ៊ុយណេដារូសាឡឹម

ព្រះរាជាណាចក្រកម្ពុជា

សាធារណរដ្ឋឥណ្ឌូនេស៊ី

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ម៉ាឡេស៊ី

សហភាពមីយ៉ាន់ម៉ារ

សាធារណរដ្ឋហ្វីលីពីន

សាធារណរដ្ឋសឹង្ហបុរី

ព្រះរាជាណាចក្រថៃឡង់ដ៍

សាធារណរដ្ឋសង្គមនិយមវៀតណាម

Commonwealth នៃអូស្ត្រាលី

សាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

សាធារណរដ្ឋប្រជាមានិតចិន

សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ

សាធារណរដ្ឋបារាំង

សាធារណរដ្ឋឥណ្ឌា

ជប៉ុន

ម៉ុងហ្គោលី

ណូវែលហ្សេឡង់

សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

ប៉ាពូញូវហ្គីណេ

សាធារណរដ្ឋកូរ៉េ

សហព័ន្ធរុស្ស៊ី

សាធារណរដ្ឋសង្គមនិយមប្រជាធិបតេយ្យស្រីលង្កា

សាធារណរដ្ឋប្រជាធិបតេយ្យទីម័រលេស្ត

សាធារណរដ្ឋទួរគី

សហរដ្ឋអាមេរិក

**តទៅនេះទទួលស្គាល់ជាភាគីហត្ថលេខីជាន់ខ្ពស់:**

**ក្នុងគោលបំណង** ដើម្បីធានាថាមានការលើកកំពស់សមស្របសំរាប់កិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រជាជាតិទាំងអស់ ដែលស្នេហាសន្តិភាពទាំងក្នុង និងក្រៅតំបន់អាស៊ីអាគ្នេយ៍ជាពិសេសប្រទេសជិតខាងនៃតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាបណ្តាអង្គការតំបន់ ដែលមានសមាជិករបស់ខ្លួនជារដ្ឋអធិបតេយ្យតែប៉ុណ្ណោះ។

**ដោយពិចារណាលើ**កថាខ័ណ្ឌ ៥ នៃបុព្វកថា របស់សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ដែលបានធ្វើនៅដែនប៉ាសា ទីក្រុងបាលី នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ (គ្រាប់ពីពេលនេះតទៅហៅថា សន្ធិសញ្ញាមិត្តភាព) ដែលសំដៅចំពោះសេចក្តីត្រូវការកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដែលស្នេហាសន្តិភាពទាំងអស់ ទាំងក្នុង និងក្រៅតំបន់អាស៊ីអាគ្នេយ៍ ក្នុងការបន្តជំរុញឱ្យមានសន្តិភាពស្ថេរភាព និងភាពសុខដុមរបស់ពិភពលោក។

**ព្រមព្រៀងគ្នាលើមាត្រា ដូចខាងក្រោមនេះ:**

**មាត្រា ១**

មាត្រា១៨ កថាខ័ណ្ឌ៣ នៃសន្ធិសញ្ញាមិត្តភាព ត្រូវធ្វើវិសោធនកម្ម ដូចតទៅ:

"សន្ធិសញ្ញានេះត្រូវបើកឱ្យរដ្ឋដទៃទៀតក្រៅតំបន់អាស៊ីអាគ្នេយ៍ និងអង្គការក្រៅតំបន់នានា ដែលមានសមាជិករបស់ខ្លួនជារដ្ឋអធិបតេយ្យតែប៉ុណ្ណោះចូលរួមក្នុងសន្ធិសញ្ញានេះ ដោយត្រូវមានការយល់ព្រមពីគ្រប់រដ្ឋទាំងអស់ក្នុងអាស៊ីអាគ្នេយ៍ដូចជា ប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ារ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម" ។

**មាត្រា ២**

មាត្រា១៤ កថាខ័ណ្ឌ២ នៃសន្ធិសញ្ញាមិត្តភាព ត្រូវធ្វើវិសោធនកម្ម ដូចតទៅ:

"ទោះជាយ៉ាងណាក៏ដោយ មាត្រានេះត្រូវអនុវត្តទៅលើរដ្ឋជាភាគីហត្ថលេខីជាន់ខ្ពស់ណាមួយ ដែលស្ថិតនៅក្រៅតំបន់អាស៊ីអាគ្នេយ៍ តែក្នុងករណីដែលរដ្ឋហត្ថលេខីជាន់ខ្ពស់នោះពាក់ព័ន្ធដោយផ្ទាល់ក្នុងជំលោះ ដែលត្រូវដោះស្រាយតាមរយៈដំណើរការតំបន់តែប៉ុណ្ណោះ ។

### មាត្រា ៣

ពិធីសារនេះត្រូវជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ហើយនឹងត្រូវចូលជាធរមាននៅថ្ងៃដែលលិខិតូបករណ៍ចុងក្រោយត្រូវបានដាក់តំកល់ដោយភាគីហត្ថលេខីជាន់ខ្ពស់ ។

ធ្វើនៅទីក្រុងហាណូយ ប្រទេសវៀតណាម ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ក្នុងសំណៅដើមជាភាសាអង់គ្លេសតែមួយ ។

# THIRD PROTOCOL AMENDING THE TREATY OF AMITY AND COOPERATION IN SOUTHEAST ASIA

Brunei Darussalam
The Kingdom of Cambodia
The Republic of Indonesia
The Lao People's Democratic Republic
Malaysia
The Union of Myanmar
The Republic of the Philippines
The Republic of Singapore
The Kingdom of Thailand
The Socialist Republic of Viet Nam
The Commonwealth of Australia
The People's Republic of Bangladesh
The People's Republic of China
The Democratic People's Republic of Korea
The French Republic
The Republic of India
Japan
Mongolia
New Zealand
The Islamic Republic of Pakistan
Papua New Guinea
The Republic of Korea
The Russian Federation
The Democratic Socialist Republic of Sri Lanka
The Democratic Republic of Timor-Leste
The Republic of Turkey
The United States of America

Hereinafter referred to as the High Contracting Parties:

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

**DESIRING** to ensure that there is appropriate enhancement of cooperation with all peace-loving nations both within and outside Southeast Asia, in particular, neighbouring States of the Southeast Asian region, as well as with regional organisations whose members are only sovereign States;

**CONSIDERING** Paragraph 5 of the preamble of the Treaty of Amity and Cooperation in Southeast Asia, done at Denpasar, Bali, on 24 February 1976 (hereinafter referred to as the Treaty of Amity) which refers to the need for cooperation with all peace-loving nations, both within and outside Southeast Asia, in the furtherance of world peace, stability and harmony;

**HEREBY AGREE TO THE FOLLOWING:**

## ARTICLE 1

Article 18, Paragraph 3, of the Treaty of Amity shall be amended to read as follows:

"This Treaty shall be open for accession by States outside Southeast Asia and regional organisations whose members are only sovereign States subject to the consent of all the States in Southeast Asia, namely, Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam."

## ARTICLE 2

Article 14, Paragraph 2, of the Treaty of Amity shall be amended to read as follows:

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

"However, this article shall apply to any of the High Contracting Parties outside Southeast Asia only in cases where that High Contracting Party is directly involved in the dispute to be settled through the regional processes."

## ARTICLE 3

This Protocol shall be subject to ratification and shall come into force on the date the last instrument of ratification of the High Contracting Parties is deposited.

**DONE** at Ha Noi, Viet Nam, on the Twenty-Third Day of July in the Year Two Thousand and Ten, in a single copy in the English language.

For Brunei Darussalam:

**MOHAMED BOLKIAH**
Minister of Foreign Affairs and Trade

For the Kingdom of Cambodia:

**HOR NAMHONG**
Deputy Prime Minister and
Minister of Foreign Affairs and International Cooperation

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Republic of Indonesia:

**DR. R.M. MARTY M. NATALEGAWA**
Minister for Foreign Affairs

For the Lao People's Democratic Republic:

**DR. THONGLOUN SISOULITH**
Deputy Prime Minister and Minister of Foreign Affairs

For Malaysia:

**DATO' SRI ANIFAH AMAN**
Minister of Foreign Affairs of Malaysia

For the Union of Myanmar:

**NYAN WIN**
Minister for Foreign Affairs

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Republic of the Philippines:

**ERLINDA F. BASILIO**
Undersecretary of Foreign Affairs

For the Republic of Singapore:

**GEORGE YONG-BOON YEO**
Minister for Foreign Affairs

For the Kingdom of Thailand:

**KASIT PIROMYA**
Minister of Foreign Affairs

For the Socialist Republic of Viet Nam:

**DR. PHAM GIA KHIEM**
Deputy Prime Minister and Minister for Foreign Affairs

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Commonwealth of Australia:

**GILLIAN BIRD**
Ambassador to ASEAN

For the People's Republic of Bangladesh:

**DIPU MONI NAWAZ**
Minister of Foreign Affairs

For the People's Republic of China:

**YANG JIECHI**
Minister of Foreign Affairs

For the Democratic People's Republic of Korea:

**PAK UI-CHUN**
Minister of Foreign Affairs



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the French Republic:

**JEAN-FRANÇOIS GIRAULT**
Ambassador Extraordinary and Plenipotentiary to Viet Nam

For the Republic of India:

**PRENEET KAUR**
Minister of State for External Affairs

For Japan:

**KATSUYA OKADA**
Minister for Foreign Affairs

For Mongolia:

**ZANDANSHATAR GOMBOJAV**
Minister for Foreign Affairs and Trade

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For New Zealand:

**MURRAY McCULLY**
Minister of Foreign Affairs

For the Islamic Republic of Pakistan:

**MAKHDOOM SHAH MAHMOOD QURESHI**
Minister of Foreign Affairs

For Papua New Guinea:

**CHRISTOPHER S. MERO**
Special Envoy of the Minister for Foreign Affairs, Trade and Immigration

For the Republic of Korea:

**YU MYUNG-HWAN**
Minister of Foreign Affairs and Trade

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

For the Russian Federation:

**SERGEY LAVROV**
Minister of Foreign Affairs

For the Democratic Socialist Republic of Sri Lanka:

**GITANJANA GUNAWARDENA**
Deputy Minister of External Affairs

For the Democratic Republic of Timor-Leste:

**ZACARIAS ALBANO DA COSTA**
Minister for Foreign Affairs

For the Republic of Turkey:

**AHMET DAVUTOĞLU**
Minister of Foreign Affairs

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SCRETARIAT
asean

For the United States of America:

HILLARY RODHAM CLINTON
Secretary of State

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៧ សជណ.កបច

# សេចក្ដីថ្លែងហេតុ
## នៃសេចក្ដីព្រាងច្បាប់
## ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្ម លើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍

កន្លងមកព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័ន លើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (Treaty of Amity and Cooperation in Southeast Asia-TAC) និងពិធីសារទី២ (Second Protocol) ធ្វើវិសោធនកម្មលើសន្ធិសញ្ញានេះ។ នៅពេលថ្មីៗនេះ ពិធីសារទី៣ (Third Protocol) ធ្វើវិសោធនកម្មលើសន្ធិសញ្ញានេះដែរ ត្រូវបានចុះហត្ថលេខាដោយបណ្ដារដ្ឋមន្ត្រីការបរទេសអាស៊ាន ព្រមទាំងដោយភាគីហត្ថលេខីទាំងអស់ក្រៅពីអាស៊ាន (លើកលែងតែកាណាដា) នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៣ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

ពិធីសារទី៣នេះ បានធ្វើវិសោធនកម្មលើមាត្រាទី១៨ កថាខណ្ឌទី៣ នៃសន្ធិសញ្ញា TAC ដើម្បីបើកផ្លូវឲ្យអង្គការតំបន់ដទៃដូចជា សហភាពអឺរ៉ុប ចូលជាភាគីនៃសន្ធិសញ្ញា TAC ដែរ។

ក្នុងមាត្រា៣ នៃពិធីសារទី៣នេះ តម្រូវឲ្យភាគីហត្ថលេខីទាំងអស់ផ្ដល់សច្ចាប័ន ហើយនឹងត្រូវចូលជាធរមាននៅថ្ងៃដែលលិខិតូបករណ៍ចុងក្រោយត្រូវបានដាក់តម្កល់នៅលេខាធិការដ្ឋានអាស៊ាន។

រហូតមកទល់ពេលនេះ មានតែប្រទេសសិង្ហបុរីមួយប៉ុណ្ណោះ ដែលបានផ្ដល់សច្ចាប័នលើពិធីសារទី៣ នេះ។

សេចក្ដីដូចបានជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី … ខែ … ឆ្នាំ ២០១១

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានសេវាច្បាប់ និងសម្ព័ន្ធភាពដែនដី
នាយកដ្ឋានស្រាវជ្រាវច្បាប់

# របាយការណ៍ស្ដាពរ
# សិក្សាស្រាវជ្រាវ វិភាគ និងជូនយោបល់លើសេចក្ដីព្រាងច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍

## I-ទិដ្ឋភាពទូទៅ

### ១.ប្រភពនៃអត្ថបទច្បាប់

ពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍នេះ បានចុះហត្ថលេខាដោយបណ្ដារដ្ឋមន្ត្រីការបរទេសអាស៊ាន ព្រមទាំងភាគីហត្ថលេខីទាំងអស់ក្រៅពីអាស៊ាន (លើកលែងតែកាណាដា) នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៣ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។ កន្លងមកព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័នលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (Treaty of Amity and Cooperation in Southeast Asia-TAC) នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥ និងពិធីសារទី២ (Second Protocol) ធ្វើវិសោធនកម្មលើសន្ធិសញ្ញានេះ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩។ សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) គឺជាសន្ធិសញ្ញាសន្តិភាពរវាងប្រទេសជាសមាជិកអាស៊ាន ដែលបង្កើតឡើងដោយសមាជិកស្ថាបនិកនៃអាស៊ាន (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ សិង្ហបុរី ហ្វីលីពីន ប្រ៊ុយណេ)។

### ២.ទម្រង់នៃសេចក្ដីព្រាងច្បាប់

សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញា មិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ មាន ២ មាត្រា។ មាត្រា ១ ចែងអំពីការយល់ព្រមទៅលើខ្លឹមសារនៃពិធីសារទី៣ ដែលចែងអំពីការធ្វើវិសោធនកម្មមាត្រាមួយចំនួននៃសន្ធិសញ្ញា មិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ដូចតទៅ:

- មាត្រា១ ចែងអំពីការធ្វើវិសោធនកម្ម មាត្រា១៨ កថាខណ្ឌ៣ នៃសន្ធិសញ្ញា។

- មាត្រា២ ចែងអំពីការធ្វើវិសោធនកម្ម មាត្រា១៤ កថាខ័ណ្ឌ២ នៃសន្ធិសញ្ញា។

- មាត្រា៣ ចែងអំពីការតំកល់ឯកសារដោយភាគីជាសមាជិកនៃកិច្ចព្រមព្រៀង។

**៣.គោលបំណង និងទិសដៅពិធីសារ**

- ពង្រឹងនូវកិច្ចសហប្រតិបត្តិការ និងជាការបើកច្រកឲ្យរដ្ឋអធិបតេយ្យដ៏ទៃទៀតក្រៅពីតំបន់អាស៊ីអាគ្នេយ៍ អាចចូលរួមក្នុងសន្ធិសញ្ញានេះបាន តែក៏ត្រូវឲ្យមានការយល់ព្រមពីប្រទេសជាសមាជិកអាស៊ានទាំងអស់ផង។
- បង្កើតនូវយន្តការដោះស្រាយទំនាក់ទំនងដោយផ្ទាល់ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញា ចំពោះភាគីជារដ្ឋហត្ថលេខីជាន់ខ្ពស់នៃកិច្ចព្រមព្រៀង ដែលរួមមានសមាជិក ២៨ ប្រទេស ក្នុងនោះសមាជិកអាស៊ានទាំង១០ និងភាគីជារដ្ឋហត្ថលេខីក្រៅតំបន់ចំនួន១៨ ផ្សេងទៀត។

**៤.វិសាលភាពអនុវត្តនៃពិធីសារ**

ពិធីសារនេះ មានវិសាលភាពគ្របដណ្តប់ ទាំងក្នុង និងក្រៅតំបន់អាស៊ីអាគ្នេយ៍ និងអង្គការក្រៅតំបន់នានា ដែលមានសមាជិករបស់ខ្លួនជារដ្ឋអធិបតេយ្យដែលជាភាគីនៃកិច្ចព្រមព្រៀងតែប៉ុណ្ណោះ ។

II-**ការអង្កេតកិច្ចប្រជុំអនុម័តលើសេចក្តីព្រាងច្បាប់របស់រដ្ឋសភា**

-កិច្ចប្រជុំប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

-សម័យប្រជុំលើកទី៦ នីតិកាលទី៤

-ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា

-អ្នកការពារអត្ថបទច្បាប់ ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**១.ការអនុម័តអត្ថបទច្បាប់របស់រដ្ឋសភា**

-កូរ៉ុមមានចំនួន ១០០រូប

-សំលេងអនុម័តលើខ្លឹមសាររួមមានចំនួន ៩៨ លើ ១០១សំលេង

-មាត្រា១ សំលេងអនុម័តយល់ព្រមមានចំនួន ៩៤ លើ ១០១ សំលេង (គ្មានការពិភាក្សា)

-មាត្រា២ សំលេងអនុម័តយល់ព្រមមានចំនួន ៩៤ លើ ១០១ សំលេង (គ្មានការពិភាក្សា)

-សំលេងអនុម័តយល់ព្រមលើអត្ថបទច្បាប់ទាំងមូលមាន ៩៤ លើ ១០១ សំលេង

**២.មតិយោបល់របស់តំណាងរាស្រ្ត**

ក្នុងមាត្រា១ មិនបានលើកយកពាក្យ យុត្តិធម៌ និងនីតិរដ្ឋទេ ដែលជាចំណុចសំខាន់ដើម្បីពង្រឹងច្បាប់ និងភាពយុត្តិធម៌សំរាប់ប្រជាពស្រ្ត។

**៣.មតិយោបល់របស់តំណាងរាជរដ្ឋាភិបាល**

ច្បាប់នេះ បានធ្វើវិសោធនកម្មចំនួនបីដង ដែលវិសោធនកម្មនោះមាន:

-វិសោធនកម្មលើកទី១ អនុញ្ញាតឲ្យប្រទេសក្រៅតំបន់ចូលរួម (ដោយកាលនោះ ប្រទេសសមាជិកអាស៊ានមានចំនួនតែ ៦ប្រទេសតែប៉ុណ្ណោះ តម្រូវឲ្យសមាជិកទាំងអស់យល់ព្រម)។

-វិសោធនកម្មលើកទី២ អនុញ្ញាតឲ្យប្រទេសក្រៅតំបន់ចូលរួម (ដោយមានការកើនឡើងនូវសមាជិកអាស៊ាន ដូច្នេះតម្រូវឲ្យសមាជិកទាំងអស់យល់ព្រម)។

-វិសោធនកម្មលើកទី៣ អនុញ្ញាតឲ្យអង្គការក្រៅតំបន់អាស៊ានចូលរួម។

## III.ការវិភាគរបស់នាយកដ្ឋានស្រាវជ្រាវច្បាប់

### ១.ធម្មនុញ្ញភាព

សេចក្តីព្រាងច្បាប់នេះ ឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម:

-មាត្រា២៦ "ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើសន្ធិញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា"។

-មាត្រា៩០ ថ្មី (២) វាក្យខ័ណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ "រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ"។

### ២.បញ្ញត្តិពាក់ព័ន្ធ

- **បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់អន្តរជាតិ**

-ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅ អាស៊ីអាគ្នេយ៍ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥។

-ព្រះរាជក្រមលេខ នស/រកម/១១៩៨/០១៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ច្បាប់ស្តីពីការអនុម័តលើពិធីសារទី២ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ទីក្រុងម៉ានីល។

### ៣.ទម្រង់នៃសេចក្តីព្រាងច្បាប់

សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ រួមមាន ២ មាត្រាត្រូវបានបញ្ជូនដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមកព្រឹទ្ធសភា ដោយអមមកជាមួយ សេចក្តីថ្លែងហេតុលេខ ១៦ សជណ.កបច ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ស្របតាមទម្រង់ច្បាប់។

### ៤.ការចូលជាធរមាននៃសេចក្តីព្រាងច្បាប់

ពិធីសារនេះ ត្រូវអោយភាគីហត្ថលេខីទាំងអស់ផ្តល់សច្ចាប័ន ហើយនឹងត្រូវចូលជាធរមាននៅថ្ងៃដែលលិខិតូបករណ៍ចុងក្រោយត្រូវបានដាក់តម្កល់នៅលេខាធិការដ្ឋានអាស៊ាន។

**៥.ចំណាប់អារម្មណ៍**

នៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តលើពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាពនេះ មានចំនួន ២មាត្រាដែលត្រូវធ្វើវិសោធនកម្ម គឺមាត្រា ១៨ កថាខណ្ឌ៣ និងមាត្រា១៤ កថាខណ្ឌ២ ហេតុអ្វីបានជាសេចក្តីព្រាងច្បាប់នេះ មិនធ្វើវិសោធនកម្មតាមលំដាប់មាត្រាដោយរាប់យកមាត្រា១៤ មុនមាត្រា ១៨ ? ។ ដោយហេតុថា កម្ពុជា និងថៃ ជាសមាជិកនៃសន្ធិសញ្ញា (TAC) តើសន្ធិសញ្ញានេះ អាចយកជាមូលដ្ឋានដើម្បីដោះស្រាយជំលោះរវាង កម្ពុជា និងថៃ បានដែរ ឬ ទេ ?

**សេចក្តីសន្និដ្ឋាន**

ពិធីសារនេះ មានសារៈសំខាន់ណាស់សំរាប់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីសហប្រតិបត្តិការជាមួយបណ្តាប្រទេសដែលស្នេហាសន្តិភាព ទាំងក្នុង និងក្រៅតំបន់អាស៊ីអាគ្នេយ៍ក្នុងការជំរុញឲ្យមានសន្តិភាព ស្ថេរភាព និងភាពសុខដុមរបស់ពិភពលោក។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ២០១១

**អ្នកធ្វើរបាយការណ៍**

**នូ ឈិន**

បានឃើញ និងឯកភាព

**ប្រធាននាយកដ្ឋាន**

**យ៉ាន់ វ៉ាន់ជីលុច**